ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស**

លេខ: ០០១/១៧ [illegible]

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
## ថ្ងៃសុក្រ ទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

នៅព្រឹកថ្ងៃសុក្រទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោង៨ និង៣០នាទី នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លង៖

**១- គម្រោងវិនិយោគខ្សែបញ្ជូនអគ្គិសនី ២៣០គីឡូវ៉ុល ពីស្ថានីយវារីអគ្គិសនីស្ទឹងតាតែមកភ្នំពេញ និងគម្រោងវិនិយោគបន្ថែមម៉ាស៊ីនផលិតអគ្គិសនីដុតធ្យូងថ្មអានុភាព១៣៥មេហ្គាវ៉ាត់ ខេត្តព្រះសីហនុ។**

**២- បញ្ហាផ្សេងៗ៖** សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ៖ «**ពិធីសារទី៣ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ នៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ ក្នុងចំណោមរដ្ឋាភិបាល នៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ**»។

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត៖

**១- គម្រោងវិនិយោគខ្សែបញ្ជូនអគ្គិសនី ២៣០គីឡូវ៉ុល ពីស្ថានីយវារីអគ្គិសនីស្ទឹងតាតែមកភ្នំពេញ និងគម្រោងវិនិយោគបន្ថែមម៉ាស៊ីនផលិតអគ្គិសនីដុតធ្យូងថ្មអានុភាព១៣៥ មេហ្គាវ៉ាត់ ខេត្តព្រះសីហនុ។**

ក្នុងគោលដៅនៃការអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាគឺការសាងសង់បណ្តាញជាតិមួយដែលមានខ្សែបណ្តាញបញ្ជូនអគ្គិសនីធំៗ និងអនុស្ថានីយតភ្ជាប់គ្នាជាមួយនឹងការសាងសង់ប្រភពអគ្គិសនីបន្ថែមជាបន្តបន្ទាប់ ដើម្បីផ្តល់ប្រភពអគ្គិសនីសម

ឱ្យបានគ្រប់គ្រាន់និងទាន់តាមកំណើននៃសេចក្តីត្រូវការប្រើប្រាស់ និងការសាងសង់បណ្តាញរង និង ចែកចាយអគ្គិសនីនៅតាមតំបន់នានាទូទាំងប្រទេសដើម្បីបញ្ជូន និងចែកចាយប្រភពអគ្គិសនីដែលបានសាងសង់ទៅផ្គត់ផ្គង់ឱ្យអ្នកប្រើប្រាស់អគ្គិសនីនៅទូទាំងប្រទេសកម្ពុជា។ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់រាជរដ្ឋាភិបាលដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី** វិស័យអគ្គិសនី របស់ព្រះរាជាណាចក្រកម្ពុជាត្រូវបានអភិវឌ្ឍរីកចំរើនទៅមុខយ៉ាងលឿន ទាំងប្រភពអគ្គិសនី អនុស្ថានីយទាំងបណ្តាញបញ្ជូនរង បណ្តាញចែកចាយ និងទាំងការភ្ជាប់ចរន្តជូនដល់លំនៅដ្ឋានរស់នៅរបស់ប្រជាពលរដ្ឋទាំងនៅទីក្រុង ទីប្រជុំជន និងទីជនបទ។

គម្រោងសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនី ២៣០គីឡូវ៉ុល ភ្ជាប់ពីស្ថានីយស្ទឹងតាតែមកអនុស្ថានីយបែកចានភ្នំពេញនេះ មិនត្រឹមតែជាការតភ្ជាប់បណ្តាញពីវារីអគ្គិសនីស្ទឹងតាតែ មកកាន់អនុស្ថានីយនៅភ្នំពេញប៉ុណ្ណោះទេ តែគឺជាការអភិវឌ្ឍមួយដែលភ្ជាប់ប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនីភាគខាងនិរតីកម្ពុជា ឱ្យក្លាយជាប្រព័ន្ធបណ្តាញកងជាមួយភ្នំពេញ ដើម្បីបង្កើននូវស្ថេរភាពភាពរឹងមាំ និងសមត្ថភាពក្នុងការបញ្ជូនប្រភពអគ្គិសនីពីស្ថានីយវារីអគ្គិសនីដែលមានទីតាំងនៅក្នុងតំបន់ត្រីកោណកំពង់ស្ពឺ កោះកុង និងពោធិ៍សាត់ និងបង្កើននូវស្ថេរភាព និងលំនឹងនៃការផ្គត់ផ្គង់អគ្គិសនីនៅរាជធានីភ្នំពេញផងដែរ។

ការវិនិយោគគម្រោងនេះ ធ្វើឡើងតាមរូបភាពគម្រោងវិនិយោគគឺ សាងសង់ ដំណើរការផ្ទេរ (BOT) ដែលមានទំហំទុនវិនិយោគសរុប ១៣៦, ៦៩លានដុល្លារអាមេរិក និងមានរយៈពេលសម្បទាន ២៨ឆ្នាំ ក្នុងនោះ៣ឆ្នាំសម្រាប់ធ្វើការសាងសង់ និង២៥ឆ្នាំ សម្រាប់ធ្វើអាជីវកម្ម។

ម្យ៉ាងវិញទៀតសម្រាប់គម្រោងវិនិយោគបន្ថែមម៉ាស៊ីនផលិតអគ្គិសនីដុតត្បូងថ្មនេះ គឺធ្វើឡើងតាមរូបភាពវិនិយោគគឺ សាងសង់ធ្វើម្ចាស់អាជីកម្ម (BOO) ដែលមានទំហំទុនវិនិយោគសរុប២៥៩.៩លានដុល្លារអាមេរិក។

**២- បញ្ហាផ្សេងៗ៖** អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានអនុម័តបញ្ជូន «**ពិធីសារទី៣ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ នៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ ក្នុងចំណោមរដ្ឋាភិបាល នៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ**»ទៅសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិ។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាបានណែនាំ៖

១.ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិ និងស្ថាប័នពាក់ព័ន្ធ ត្រូវចេញវិធានការណែនាំដ៏ម៉ឺងម៉ាត់ និងជាបន្ទាន់ឱ្យ ធនាគារឯកជន និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាពិសេសប្រព័ន្ធផ្សព្វ

ផ្សាយ និងបណ្តាញទូរគមនាគមន៍ទាំងអស់ ដើម្បីពន្យល់ប្រជាពលរដ្ឋឱ្យបានដឹងច្បាស់ថា "ធនាគារឯកជន មីក្រូហិរញ្ញវត្ថុ គឺជាគ្រឹះស្ថានហិរញ្ញវត្ថុរបស់ឯកជនមួយរយភាគរយ ហើយមិនមែនជារបស់រដ្ឋ" ឡើយ។

២. សម្តេចតេជោ នាយករដ្ឋមន្ត្រី ក៏បានដាក់បទបញ្ជាយ៉ាងម៉ឺងម៉ាត់ជាទីបំផុតដល់អាជ្ញាធរថ្នាក់ក្រោមជាតិ រួមមានៈ អាជ្ញាធរ រាជធានី ខេត្ត ក្រុង ខ័ណ្ឌ ស្រុក ឃុំ សង្កាត់ និងភូមិ ទាំងស៊ីវិល នគរបាល និងកងរាជអាវុធហត្ថ ត្រូវបញ្ឈប់ និងដកខ្លួនជាបន្ទាន់ ពីការចូលរួមធ្វើសកម្មភាពណាមួយជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកជន ដែលនាំឱ្យប្រជាពលរដ្ឋមានការយល់ច្រឡំថាជារបស់រដ្ឋ ដែលការពិត គឺជារបស់ឯកជនសុទ្ធសាធ។

៣.ក្រសួងពាណិជ្ជកម្ម ត្រូវធ្វើការជាបន្ទាន់ជាមួយធនាគារអេស៊ីលីដា ដែលបាន និងកំពុងប្រើរូបសញ្ញា "ហង្ស" ជានិមិត្តសញ្ញាពាណិជ្ជកម្មរបស់ខ្លួន ឱ្យធ្វើការផ្លាស់ប្តូររូបសញ្ញាហង្សនេះជាបន្ទាន់ ក្នុងរយៈពេល៣ សប្តាហ៍យ៉ាងយូរ ពីព្រោះ "រូបហង្ស" គឺជារូបសញ្ញារបស់ជាតិ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាន និងកំពុងប្រើប្រាស់ ចៀសវាងការយល់ច្រឡំរបស់ប្រជាពលរដ្ឋ។

ទន្ទឹមនឹងការផ្តាំផ្ញើសួរសុខទុក្ខកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលកំពុងឈរជើងតាមបណ្តោយព្រំដែន សម្តេចតេជោ នាយករដ្ឋមន្ត្រី ក៏បានក្រើនរំលឹកផងដែរឱ្យយកចិត្តទុក ថែទាំសុខភាពក្នុងពេលដែលអាកាសធាតុកំពុងចុះត្រជាក់នេះ។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង ១០និង ៣០នាទី។

រាជធានីភ្នំពេញ, ថ្ងៃសុក្រ ទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧